Trial on 22 April 2022
- clerk. Dalin
- Salle : 2

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៩៣/២៣-០២-២០២១

សាលដីកា

លេខ ៨០ ក្រ"ណ"/១២-១១-២១

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១ (៨"០០) ដោយមានសមាសភាពដូចខាងក្រោម ៖

ក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

កញ្ញា ទីវ គឹមកល្យាណ ជាព្រះរាជអាជ្ញា

ក្រឡាបញ្ជីសវនាការ

លោក ទី ចិត្តត្រា

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៣ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានជនជាប់ចោទ ៖

១/ឈ្មោះ [redacted] ដារ៉ា ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់គ្រឿងញៀន ទីកន្លែងកំណើតនៅឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ទីលំនៅមុនពេលឃុំខ្លួន [redacted] ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ "PJ" (ប្ដឹងឧទ្ធរណ៍) ។

មានឈ្មោះ [redacted] កនិកា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

២/ឈ្មោះ [redacted] ថាវរិន ហៅ ទូច ភេទប្រុស អាយុ ៣៥ ឆ្នាំ ជនជាតិខ្មែរ មុខរបរមេការ ទីកន្លែងកំណើតនៅឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ទីលំ [redacted]





Scanned with CamScanner

៥៦៤ ភូមិ ១ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន "ក្រៅឃុំ" (ប្តឹងឧទ្ធរណ៍) ។

មានឈ្មោះ [redacted] ធារី ឈ្មោះ [redacted] ច័ន្ទសីហា និងឈ្មោះ [redacted] ចាន់ដារ៉ា មេធាវីការពារ។

៣/ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ២៩ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ មានទីលំនៅសព្វថ្ងៃភូមិបាពយណ៍ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ "ក្រៅឃុំ" (ប្តឹងឧទ្ធរណ៍) ។

មានឈ្មោះ [redacted] ច័ន្ទតារាវុធ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ជាប់ចោទពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្លាយ) ផ្លូវកែវចិន្តា ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤/ឈ្មោះ [redacted] ធារី ភេទស្រី អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរមេការ ទីកន្លែងកំណើតនៅភូមិព្រៃឆ្លាក់ ខេត្តស្វាយរៀង ទីលំនៅមុនពេលឃុំខ្លួនស្ន[redacted] ៣៥៧ សង្កាត់ច្បារអំពៅ ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ សួន សំបូរ មានកូន ០៣ នាក់ ទោសពីមុនគ្មាន ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ "PJ" (ប្តឹងឧទ្ធរណ៍) ។

មានឈ្មោះ [redacted] ប៉ូលីន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៥/ឈ្មោះ [redacted] យ៉ន ភេទប្រុស អាយុ ៥០ ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកបររថយន្ត ទីកន្លែងកំណើតនៅភូមិចុងកាល់ ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ទីលំនៅមុន [redacted] ភូមិជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២ នាក់ ទោសពីមុនគ្មាន ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ "PJ" (ប្តឹងឧទ្ធរណ៍)។

មានឈ្មោះ [redacted] ប៉ូលីន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ជាប់ចោទពីបទ៖ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្លាយ) ផ្លូវកែវចិន្តា ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦/ឈ្មោះ [redacted] ធីតា ភេទស្រី អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍) ។

Scanned with CamScanner

៧/ឈ្មោះ [redacted] លីថេង ភេទប្រុស អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍) ។

៨/ឈ្មោះ [redacted] សុនីន ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍) ។

ឯរឿងហេតុមានដូចតទៅ

**សកម្មភាព**ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖

មុនពេលកើតហេតុនោះ ឈ្មោះ [redacted] ថាវរិន បានបើកក្លឹបកំសាន្តឈ្មោះ **FLY** "ផ្លាយ" (ចំណុចកើតហេតុ) ដើម្បីឲ្យជនរងគ្រោះដែលមកលេងក្នុងក្លឹបកំសាន្តអាចទិញគ្រឿងញៀនយកទៅប្រើប្រាស់បាន តាមរយៈបក្សពួករបស់ឈ្មោះ [redacted] ដារ៉ា ឈ្មោះ [redacted] តនា ឈ្មោះ ថៃ និងឈ្មោះ ឡុង ដែលបានរៀបចំទុករួចជាស្រេច និងមានការសម្រួលពីបុគ្គលិកនៅក្នុងក្លឹបកំសាន្តនោះ គឺឈ្មោះ [redacted] ធារី ឈ្មោះ [redacted] យ៉ន ឈ្មោះ [redacted] ធីតា ឈ្មោះ [redacted] លីថេង ឈ្មោះ [redacted] សុនីន និងឈ្មោះ រ៉ា ។

លុះដល់ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង ២.៣០ នាទីយប់ កម្លាំងនគរបាលនៃការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល បានសហការជាមួយកម្លាំងនគរបាលអន្តរាគមន៍កងពិសេសនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចុះទៅបង្ក្រាបទីតាំងខាងលើ និងចាប់យកនូវវត្ថុតាង គឺ ៖

ដកហូតពីជនល្មើសឈ្មោះ [redacted] ដារ៉ា មានដូចខាងក្រោម ៖

-ម្សៅក្រាមពណ៌សថ្លាចំនួន ១០១ កញ្ចប់ សរុបទម្ងន់ ២៤,៣៥ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ កេតាមីន ។

-ថ្នាំគ្រាប់ពណ៌ស្វៃចំនួន ៣២ គ្រាប់ សរុបទម្ងន់ ១២,០៧ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ អឹមដេអឹមអា និង មេតំហ្វេតាមីន ។

-ថ្នាំគ្រាប់ពណ៌ត្រួយចេកចំនួន ១០ គ្រាប់ សរុបទម្ងន់ ៤,៣៨ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ អឹមដេអឹមអា ។

ដកហូតពីជនល្មើសឈ្មោះ [redacted] ធារី មានដូចខាងក្រោម ៖

-ម៉ៅម៉ដ្ឋពណ៌សចំនួន ៣៥ កញ្ចប់ សរុបទម្ងន់ ៧,៩៦ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ កេតាមីន ។

-ថ្នាំគ្រាប់ពណ៌ស្វៃចំនួន ១២ គ្រាប់ សរុបទម្ងន់ ៤,៥៨ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ អឹមដេអឹមអា និង មេតំហ្វេតាមីន ។

-ថ្នាំគ្រាប់ពណ៌ត្រួយចេកចំនួន ០៧ គ្រាប់ សរុបទម្ងន់ ២,៥៩ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ អឹមដេអឹមអា ។

បន្ទាប់មកសមត្ថកិច្ចបាននាំខ្លួនជនល្មើសឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ធារី រួមទាំងបក្សពួកឈ្មោះ [redacted] យ៉ន ឈ្មោះ [redacted] តា ឈ្មោះ [redacted] លីថេង និងឈ្មោះ [redacted] សុនីន ព្រមទាំងភស្តុតាងដែលពាក់ព័ន្ធទាំងអស់ បញ្ជូនទៅការិយាល័យព្រហ្មទណ្ឌកំរិតស្រាលនៃ



Scanned with CamScanner

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ចំណែកមេខ្លោងជួញដូរគ្រឿងញៀន និងបក្សពួកផ្សេងទៀត បានរត់គេចខ្លួន ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ១៩០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ឲ្យជនជាប់ចោទ ៖

ក/ឈ្មោះ [redacted] លីថេង ភេទប្រុស អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ

ខ/ឈ្មោះ [redacted] សុនីន ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ

គ/ឈ្មោះ [redacted] ធីតា ភេទស្រី អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ

រួចខ្លួនពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្លាយ) ផ្លូវកែវចិន្តា ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ, មាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ផ្តន្ទាទោសលើជនជាប់ចោទ ៖

ក/ឈ្មោះ [redacted] ចាវិន ហៅ ទូច ភេទប្រុស អាយុ ៣៥ ឆ្នាំ ជនជាតិខ្មែរ

ខ/ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ២៩ ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារម្នាក់ៗ កំណត់រយៈពេល ០៧ (ប្រាំពីរ) ឆ្នាំ និងពិន័យជាប្រាក់ម្នាក់ៗចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។

គ/ឈ្មោះ [redacted] ដារ៉ា ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្លាយ) ផ្លូវកែវចិន្តា ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៥ ចំណុច ១១ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ/ឈ្មោះ [redacted] ចារី ភេទស្រី អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

ង/ឈ្មោះ [redacted] យ៉ន ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

ពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្លាយ) ផ្លូវកែវចិន្តា ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ តាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

4

Scanned with CamScanner

៣-បង្គាប់ឲ្យសមត្ថកិច្ចចាប់ឃុំខ្លួនឈ្មោះ [redacted] ថាវិន ហៅ ទូច ភេទប្រុស អាយុ ៣៥ ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ២៩ ឆ្នាំ ជនជាតិខ្មែរ យកមកដាក់ពន្ធនាគារតាមអំណាចសាលក្រមនេះ ។

៤-វត្ថុចាប់យកក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៥០៨ រ.វ.ត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២០ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន ៖

ក/ម៉ូតូម៉ាកយ្យូប៊ិច ពណ៌ខៀវ ពាក់ស្លាកលេខ ភ្នំពេញ 1HT-2976

ខ/ទូរស័ព្ទដៃមួយគ្រឿងម៉ាក Iphone ពណ៌ទឹកមាស

គ/ទូរស័ព្ទដៃមួយគ្រឿងម៉ាក Iphone ពណ៌ទឹកប្រាក់

សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥-វត្ថុចាប់យកក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៥០៨ រ.វ.ត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២០ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន ៖

៥.១/ស្រោមសំបុត្របិទជិត ពណ៌លឿង ចំនួន ០១ (មួយ) ដែលមានសរសេរថា ៖

ក/ម៉្សៅម៉ដ្ឋពណ៌សថ្លាចេញពណ៌ស្វាយ សង្ស័យមានតម្រុយជាគ្រឿងញៀន ប្រភេទកេតាមីន ទម្ងន់ ៧,៩៦ (ប្រាំពីរកណ្តក់សញ្ញាកៅសិបប្រាំមួយ) ក្រាម ។

ខ/ថ្នាំក្រាមពណ៌ស្លែចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀន ប្រភេទអ៊ិចស្តាស៊ី ទម្ងន់ ៤,៥៨ (បួនកណ្តក់សញ្ញាហាសិបប្រាំបី) ក្រាម ។

គ/ថ្នាំក្រាមពណ៌ត្រួយចេកចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀន ប្រភេទអ៊ិចស្តាស៊ី ទម្ងន់ ២,៥៤ (ពីរកណ្តក់សញ្ញាហាសិបប្រាំបួន) ក្រាម ។

ឃ/ដបពណ៌ខ្មៅមានទឹក ពុំបានដកធ្វើតេស្ត និងសំបកថង់ប្លាស្ទិកចំនួន ៣៧ (សាមសិបប្រាំពីរ) ដោយមានស្នាមផ្តិតមេដៃរបស់ឈ្មោះ [redacted] ធារី និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

៥.២/ស្រោមសំបុត្របិទជិត ពណ៌លឿង ចំនួន ១ (មួយ) ដែលមានសរសេរថា ៖

ក/ដុំក្រាមពណ៌សថ្លាចេញពណ៌ស្វាយ សង្ស័យមានតម្រុយជាគ្រឿងញៀន ប្រភេទកេតាមីន ទម្ងន់ ២៤,៣៥ (ម្ភៃបួនកណ្តក់សញ្ញាហាមសិបប្រាំ) ក្រាម ។

ខ/ថ្នាំគ្រាប់ពណ៌ស្លែចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀន ប្រភេទអ៊ិចស្តាស៊ី ទម្ងន់ ១២,០៧ (ដប់ពីរកណ្តក់សញ្ញាសូន្យប្រាំពីរ) ក្រាម ។

គ/ថ្នាំគ្រាប់ពណ៌ត្រួយចេកចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀន ប្រភេទ អ៊ិចស្តាស៊ី ទម្ងន់ ៤,៣៨ (បួនកណ្តក់សញ្ញាសាមសិបប្រាំបី) ក្រាម និងសំបកថង់ប្លាស្ទិកចំនួន ១០៥ (មួយរយប្រាំ) ដោយមានស្នាមផ្តិតមេដៃរបស់ឈ្មោះ [redacted] ដារ៉ា និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

៥.៣/ម៉ូតូម៉ាកហុងដាស្កុបពី ពណ៌សលាយព្រីងទុំ ពាក់ស្លាកលេខ ភ្នំពេញ 1BB-1080 ចំនួន ០១ (មួយ) គ្រឿង "មិនប្រក្រតី" ។

5

Scanned with CamScanner

៥.៤/រថយន្តម៉ាកតូយូតាព្រុស ពណ៌ខៀវ ពាក់ស្លាកលេខ ភ្នំពេញ 2AR-2984 ចំនួន ០១ (មួយ) គ្រឿង "មិនប្រក្រតី" ។

៥.៥/ទូរស័ព្ទដៃម៉ាក Huawei ពណ៌ខ្មៅ ចំនួន ០១ (មួយ) គ្រឿង "មិនដំណើរការ"

៥.៦/ទូរស័ព្ទដៃម៉ាក Iphone ពណ៌ទឹកប្រាក់ ចំនួន ០១ (មួយ) គ្រឿង "មិនដំណើរការ"

៥.៧/ទូរស័ព្ទដៃម៉ាក Oppo ពណ៌ទឹកប៊ិច ចំនួន ០១ (មួយ) គ្រឿង "មិនដំណើរការ"

៥.៨/ទូរស័ព្ទដៃម៉ាក Huawei ពណ៌ទឹកសមុទ្រ ចំនួន ០១ (មួយ) គ្រឿង "មិនដំណើរការ"

៥.៩/ប្រាក់ដុល្លារចំនួន ៥៧០ (ប្រាំរយចិតសិប) ដុល្លារអាមេរិក

៥.១០/ប្រាក់ដុល្លារចំនួន ១៧០ (មួយរយចិតសិប) ដុល្លារអាមេរិក

៥.១១/ប្រាក់រៀលចំនួន ១.២០០.០០០ (មួយលានពីររយពាន់) រៀល

៥.១២/ប្រាក់រៀលចំនួន ១.២០០.០០០ (មួយលានពីររយពាន់) រៀល

៥.១៣/ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន ០១ (មួយ) "មិនដំណើរការ"

៥.១៤/ឧបករណ៍ជក់គ្រឿងញៀនចំនួន ០១ (មួយ)

៥.១៥/ម៉ូនីទ័រចំនួន ០១ (មួយ) គ្រឿង "មិនដំណើរការ"

៥.១៦/CPU ម៉ាកខៃលចំនួន ០១ (មួយ) "មិនដំណើរការ"

៥.១៧/ម៉ាស៊ីនម៉ាក EPSON ចំនួន ០១ (មួយ) "មិនដំណើរការ"

៥.១៨/ម៉ាស៊ីនព្រីនវិកយប័ត្រចំនួន ០២ (ពីរ) គ្រឿង "មិនដំណើរការ"

៥.១៩/អាយកូបម៉ាក TYT ពណ៌ខ្មៅ ចំនួន ៥ (ប្រាំ)

៥.២០/ឯកសារពាក់ព័ន្ធមួយចំនួន ។

សម្រេចរឹបអូស តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

៦-ទីតាំងដីឡូត៍ និងអាគារនៅផ្លូវកែវចិន្តា ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដែលមានកិច្ចសន្យាស្តីពីការជួលទីតាំងដីឡូត៍ និងអាគារ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៨ ធ្វើឡើងរវាងលោកជំទាវឧកញ៉ា [redacted] វុទ្ធី និងឈ្មោះ [redacted] ថាវរិន ដែលចុះហត្ថលេខា និងប្រថាប់ត្រាដោយមេធាវី [redacted] វណ្ណយ និងមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២១១០២០៣-១៤៩០ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៨ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ។

សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា ៩៤ កថាខណ្ឌ ៣ និងមាត្រា ៩៦ កថាខណ្ឌ ៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ឈ្មោះ [redacted] ធារី ឈ្មោះ [redacted] យ៉ន ឈ្មោះ [redacted] ធីតា ឈ្មោះ [redacted] បីចេង ឈ្មោះ [redacted] សុនីន មេធាវី [redacted] ហៃ មេធាវី [redacted] ដានី មេធាវី [redacted] ពស្វត់ មេធាវី [redacted] វី មេធាវី [redacted] ដានិត មេធាវី [redacted] កនិកា មេធាវី [redacted] ណារី មេធាវី [redacted] ស៊ីលវីយោ មេធាវី [redacted] ពៅដារ៉ា មេធាវី [redacted] ឡាង និងមេធាវី [redacted] ហ្សីនី កំបាំងមុខជនជាប់ចោទ



Scanned with CamScanner

ឈ្មោះ [redacted] ថាវិន ហៅ [redacted] ឈ្មោះ [redacted]តនា និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ គូភាគីមានសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០០៨ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ន ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៨០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចសេចក្ដីសម្រេចទាំងមូល ។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០៣៣ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] កនិកា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៨០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចសេចក្ដីសម្រេចទាំងមូល ។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០៥៨ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១ ៨០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចសេចក្ដីសម្រេចទាំងមូល ។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០៦២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] ច័ន្ទសីហា និងឈ្មោះ [redacted] ចាន់ដារ៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាវិន ឈ្មោះ [redacted] តេនា ឈ្មោះ [redacted] យ៉ន និងឈ្មោះ [redacted]ារី ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៨០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចសេចក្ដីសម្រេចទាំងមូល ។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០៦៤ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] ស៊ីលវីយ៉ោ និងឈ្មោះ [redacted] ពៅដារ៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាវិន ហៅ ទូច ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៨០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចសេចក្ដីសម្រេចទាំងមូល ។

**បានឃើញ**របាយការណ៍រឿង ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ភ្នំពេញ ។

**បានឃើញ**សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿង

-ឈ្មោះ [redacted] ដារ៉ា ជាជនជាប់ចោទឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍មកដោយសារទោសធ្ងន់ធ្ងរពេក ។ ខ្លួនសុំឲ្យសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចដាក់ទោសត្រឹមតែចំនួន ០៣ (បី) ឆ្នាំ ហើយចំពោះប្រាក់ពិន័យ គឺ សុំឲ្យសាលាឧទ្ធរណ៍ភ្នំពេញ ពិន័យត្រឹមតែចំនួន ៣.០០០.០០០

Scanned with CamScanner

(បីលាន) រៀល បានហើយ ។ ខ្លួនធ្វើការក្នុងក្លឹបកំសាន្តនោះ ជាអ្នករត់តុ ហើយពេលភ្ញៀវត្រូវការគ្រឿងញៀន គឺខ្លួនបានទៅយកពីឈ្មោះ [redacted] យ៉ន មកប្រគល់ឲ្យភ្ញៀវ និងយកលុយពីភ្ញៀវទៅឲ្យឈ្មោះ [redacted] យ៉ន វិញ តែពេលឈ្មោះ [redacted] យ៉ន មិននៅ, ខ្លួនឲ្យលុយនោះ ទៅឲ្យឈ្មោះ [redacted] ធារី ។ ពេលយកថ្នាំញៀនឲ្យភ្ញៀវម្តង គឺខ្លួនទទួលបានប្រាក់កម្រៃចំនួន ៥.០០០ រៀល ។ ខ្លួនក៏ធ្លាប់យកគ្រឿងញៀនពីឈ្មោះ [redacted] ធារី ឲ្យភ្ញៀវដែរ ពេលដែលឈ្មោះ [redacted] យ៉ន មិននៅ ។ ខ្លួនចូលធ្វើការនៅក្លឹបកំសាន្តនោះ បានចំនួន ៤-៥ ថ្ងៃ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-ឈ្មោះ [redacted] ធារី ជាជនជាប់ចោទឆ្លើយថា ខ្លួនយល់ព្រមទទួលឈ្មោះ [redacted] ប៉ូលីន ធ្វើជាមេធាវីការពារសិទ្ធិឲ្យខ្លួន ។ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយចំពោះចម្លើយដែលឈ្មោះ [redacted] ដារ៉ា ឆ្លើយដាក់បន្ទុកមកលើខ្លួននេះ ខ្លួនសូមបដិសេធចោល ។ ចំពោះលុយដែលសមត្ថកិច្ចដកហូតយកទៅនោះ ជាលុយដែលបានមកពីការលក់ភេសជ្ជៈ បារី និងស្ករកៅស៊ូ ។ នៅក្នុងក្លឹបកំសាន្តនោះ ខ្លួនជាអ្នកមើលអ្នកធ្វើអនាម័យ ព្រោះមិនទាន់មានកែសសៀ (គណនីគិតលុយ-ទទួលលុយ) ទើបគេឲ្យខ្លួនធ្វើកែសសៀចាំទទួលលុយសិន ទំរាំតែរកបានកែសៀ អញ្ចឹងខ្លួនពុំដែលបានដើរទៅកន្លែងតុភ្ញៀវទេ គឺចាំទទួលលុយនៅកន្លែងកែសសៀរហូត ។ ពេលដែលសមត្ថកិច្ចឲ្យខ្លួនផ្តិតមេដៃលើកំណត់ហេតុទទួលស្គាល់វត្ថុតាង គឺសមត្ថកិច្ចមិនបានអានឲ្យខ្លួនស្តាប់ឡើយ ហើយភ្នែករបស់ខ្លួនក៏មើលឆ្ងាយពុំសូវឃើញ (ភ្នែកមញ៉ូប) ។ ក្នុងក្លឹបកំសាន្តនោះ មានកាំម៉ារ៉ាគ្រប់កន្លែង, បើសិនជាខ្លួនរកស៊ីជួញដូរគ្រឿងញៀនមែន គឺពិតជាមាន (ថតបាន) នៅក្នុងកាំម៉ារ៉ាហើយ ។ ខ្លួនសំណូមពរឲ្យតុលាការលើកលែងចោទប្រកាន់ ព្រោះខ្លួនមិនបានប្រព្រឹត្តទេ ។

ចំពោះឈ្មោះ [redacted] ដារ៉ា ឆ្លើយថា យកគ្រឿងញៀនពីខ្លួន និងយកលុយមកឲ្យខ្លួននោះ គឺមិនពិតទេ ខ្លួនសូមបដិសេធ ។ ខ្លួនពុំដែលបានទទួលលុយពីឈ្មោះ យ៉ាង ដារ៉ា ហើយខ្លួនក៏គ្មានគ្រឿងញៀនដែរ ។ កាលពីឆ្នាំ ២០១៩ (ថៅកែចាស់) ខ្លួនចូលធ្វើការបានមួយខែ គេក៏បិទក្លឹបកំសាន្តនោះទៅ ហើយពេលថៅកែថ្មីបើកក្លឹបវិញ គេបានហៅខ្លួនឲ្យចូលធ្វើការជាថ្មី បានមួយរយៈក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ នៅក្លឹបកំសាន្តនោះ ខ្លួនធ្វើជាកែសសៀ តែនៅពេលមិនទាន់មានភ្ញៀវចូលក្លឹបកំសាន្តទេ គេឲ្យខ្លួនជួយមើលអ្នកអនាម័យ តើសំអាតស្អាត ឬមិនស្អាត់ ។ នៅពេលមានភ្ញៀវចូលកំសាន្ត ទើបខ្លួនមកកន្លែងកែសសៀវិញ ។ នៅក្នុងក្លឹប គឺខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] ដារ៉ា នេះទេ តែខ្លួនឃើញគាត់ចេញចូលក្នុងក្លឹប ។

ខ្លួនមិនដែលបានប្រគល់គ្រឿងញៀន ឬទទួលលុយពីគាត់ ([redacted] ដារ៉ា) ទេ ។ ខ្លួនធ្វើការទទួលបានប្រាក់ខែចំនួន ៣០០ ដុល្លារ ក្នុងមួយខែ ។ ខ្លួនមិនដែលស្គាល់ ឬជួបជាមួយថៅកែក្លឹបថ្មីទេ តែចំពោះថៅកែក្លឹបចាស់ខ្លួនធ្លាប់ស្គាល់ ។ ឈ្មោះ [redacted] យ៉ន គាត់ធ្វើការនៅក្លឹបកំសាន្តដែរ តែខ្លួនមិនដឹងថា គាត់កាន់ផ្នែកអី មានតួនាទីអ្វីទេ ឃើញតែគាត់ដើរចុះដើរឡើងនៅក្នុងក្លឹប ។

-ឈ្មោះ [redacted] យ៉ន ជាជនជាប់ចោទឆ្លើយថា ខ្លួនយល់ព្រមទទួលឈ្មោះ [redacted] ប៉ូលីន ធ្វើជាមេធាវីការពារសិទ្ធិឲ្យខ្លួន ។ ខ្លួនប្តឹងឧទ្ធរណ៍មកដោយសារទោសធ្ងន់ធ្ងរពេក ។ ខ្លួនសុំ

ឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោសមកនៅត្រឹម ០២ (ពីរ) ឆ្នាំ ចំណែកប្រាក់ពិន័យវិញ សុំឲ្យតុលាការលើកចោល ព្រោះនៅសាលាដំបូងបានសម្រេចរឹបអូសយកឡានព្រួសរបស់ខ្លួនចំនួន ០១ គ្រឿង ហើយ ។ ខ្លួនចូលធ្វើការពីម៉ោង ៩ ដល់ម៉ោង ១២ យប់ ហើយបន្ទាប់ពីម៉ោង ១២ យប់ ទៅមានអ្នកផ្សេងបន្តពីខ្លួនទៀត គឺគេឲ្យប្រាក់ខ្លួនមួយយប់ចំនួន ២០ ដុល្លារ ខ្លួនទើបតែចូលធ្វើការបាន ០២ (ពីរ) ថ្ងៃ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ពេលខ្លួនចូលធ្វើការដំបូង គឺឈ្មោះ[redacted]ធារី ជាអ្នកបង្ហាញបន្ទប់ដាក់ម៉េ្យា ស និងប្រាប់ខ្លួនថា បើមានភ្ញៀវត្រូវការម៉េ្យា ស គឺឲ្យមកយកជូនភ្ញៀវ តែខ្លួនមិនដឹងថា ម៉េ្យា ស នោះ ជាគ្រឿងញៀនទេ ។

ខ្លួនសូមបដិសេធគ្រប់ចំណុចដែលឈ្មោះ[redacted] ដារ៉ា ឆ្លើយថា យកលុយមកប្រគល់ឲ្យខ្លួននោះ មិនត្រឹមត្រូវទេ ។ ខ្លួនមិនបានយកម៉េ្យា ស ទៅប្រគល់ឲ្យឈ្មោះ[redacted]ដារ៉ា ទេ គឺឈ្មោះ[redacted]ដារ៉ា ទៅយកម៉េ្យា ស នោះ ជាមួយខ្លួនដល់ក្នុងបន្ទប់តែម្តង ដោយខ្លួនមិនដឹងថា ជាម៉េ្យាអ្វីឡើយ ។ ខ្លួនមានជម្ងឺបេះដូងតាំងពីឆ្នាំ ២០១៧ មានកូនស្រីក្នុងបន្ទុកចំនួន ០២ នាក់ និងជំពាក់បំណុលធនាគារចំនួន ៩១.៣០០ ដុល្លារ ។ ខ្លួនពុំដែលស្គាល់ថៅកែក្លឹបទេ ព្រោះខ្លួនទើបចូលធ្វើបានរយៈពេល ០២ ថ្ងៃ ប៉ុណ្ណោះ ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា សមត្ថកិច្ចបានចុះទៅបង្ក្រាបទីតាំងក្លឹបកំសាន្តផ្កាយ និងដកហូតបានវត្ថុតាងគ្រឿងញៀនពីជនជាប់ចោទ ។ តំណាងមហាអយ្យការក្រោយពីបានពិនិត្យសំណុំរឿង និងស្តាប់ការសួរដេញដោលនៅក្នុងអង្គសវនាការនេះ យល់ឃើញថា ការសម្រេចសេចក្តីរបស់សាលាដំបូង មានលក្ខណៈត្រឹមត្រូវហើយ ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

-ឈ្មោះ [redacted] កនិកា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនការពារក្តីឲ្យឈ្មោះ [redacted]ដារ៉ា ហើយខ្លួនបានដាក់សេចក្តីសន្និដ្ឋានការពារ ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០២១ ជូនក្រុមប្រឹក្សាពិនិត្យពិចារណារួចហើយ ដូច្នេះ ខ្លួនសុំរក្សាសេចក្តីសន្និដ្ឋាននោះ ទុកជាបានកាដដែល ។ នៅពេលសវនាការនេះ កូនក្តីខ្លួនបានឆ្លើយសារភាព និងសុំបន្ធូរបន្ថយទោស ព្រមទាំងសំណាង គឺសុំឲ្យសាលាឧទ្ធរណ៍ដាក់ទោសត្រឹមចំនួន ០៣ (បី) ឆ្នាំ ចំណែកប្រាក់ពិន័យ សុំឲ្យសាលាឧទ្ធរណ៍ពិន័យត្រឹមចំនួន ៣.០០០.០០០ (បីលាន) រៀល ។

បើពិនិត្យលើអង្គហេតុនៃរឿងក្តីនេះ គ្រឿងញៀនមិនមែនជារបស់កូនក្តីខ្លួនទេ កូនក្តីខ្លួនគ្រាន់តែទៅយកឲ្យភ្ញៀវ ហើយទទួលបានប្រាក់កម្រៃចំនួន ៥.០០០ រៀល និងទើបចូលធ្វើបានរយៈពេល ៤-៥ ថ្ងៃ ប៉ុណ្ណោះ ។ កូនក្តីខ្លួនមានជីវភាពខ្វះខាត ត្រូវការប្រាក់សិក្សា ទើបកូនក្តីខ្លួនប្រព្រឹត្តខុសបែបនេះ, ចូលធ្វើការបានតែ ៤-៥ ថ្ងៃ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

កូនក្តីខ្លួនមានឪពុកម្តាយចាស់ ត្រូវការកូនជួយមើលថែទាំ ។ កូនក្តីខ្លួនទើបតែប្រព្រឹត្តជាលើកទីមួយ និងបានឆ្លើយសារភាពហ្មត ហេតុដូច្នេះ សុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស និងសំណាង តាមសំណូមពររបស់កូនក្តីខ្លួន ដោយផ្អែកតាមមាត្រា ៩៣ មាត្រា ៩៤ មាត្រា ៣២ និងមាត្រា ៣៣ ដោយក្តីអនុគ្រោះ ។



Scanned with CamScanner

-ឈ្មោះ [redacted] ប៉ូលីន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនការពារក្តីឲ្យឈ្មោះ [redacted] ផារី និងឈ្មោះ [redacted] យ៉ន ។ នៅពេលសវនាការនេះ កូនក្តីខ្លួនឈ្មោះ [redacted] យ៉ន បានឆ្លើយសារភាពទទួលស្គាល់កំហុស ហើយសុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស និងសុំឲ្យលុបចោលប្រាក់ពិន័យ ។ កូនក្តីខ្លួនបានឆ្លើយសារភាព និងបានសហការណ៍ជាមួយសមត្ថកិច្ច ដើម្បីឈានទៅរកមេក្លោងផ្សេងទៀត ។ កូនក្តីខ្លួនឈ្មោះ [redacted] យ៉ន ទើបតែចូលធ្វើការបានរយៈពេល ០២ ថ្ងៃ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង អញ្ចឹងគាត់មិនបានដឹងការងារក្នុងក្លឹបនោះច្បាស់ឡើយ ហើយគាត់ក៏បានបញ្ជាក់ថា ម៉ៅ្យ ស ដែលឈ្មោះ [redacted] ដាក់យកទៅឲ្យភ្ញៀវនោះ មិនដឹងជាម៉ៅ្យអ្វីទេ ព្រោះទើបចូលធ្វើការបាន ០២ ថ្ងៃ ។ កូនក្តីឈ្មោះ [redacted] យ៉ន បានឆ្លើយសារភាព និងមានជម្ងឺបេះដូងប្រចាំកាយតាំងពីឆ្នាំ ២០១៧ មកផង, មានកូនស្រីតូចក្នុងបន្ទុកចំនួន ០២ នាក់ ហើយជំពាក់បំណុលធនាគារចំនួន ៨១.៣០០ ដុល្លារ ហេតុដូច្នេះ សុំឲ្យសាលាឧទ្ធរណ៍ភ្នំពេញ មេត្តាសម្រេចតាមសំណូមពររបស់កូនក្តីខ្លួនឈ្មោះ [redacted] យ៉ន ដើម្បីឆាប់បានចេញមកជួយរកស៊ីចិញ្ចឹមកូនស្រី និងរកប្រាក់សងបំណុលធនាគារ ចំណែកកូនក្តីខ្លួនឈ្មោះ [redacted] ផារី បានឆ្លើយបដិសេធថា គាត់មិនប្រព្រឹត្តដូចការចោទប្រកាន់នោះទេ និងសុំឲ្យតុលាការលើកលែងចោទប្រកាន់ ។ កូនក្តីខ្លួនឈ្មោះ [redacted] ផារី គាត់ជាអ្នកកាន់លុយ (គណនី) ប៉ុណ្ណោះ គឺគាត់មិនបានលក់គ្រឿងញៀនទេ ដូចគាត់បញ្ជាក់នៅពេលសវនាការនេះថា គាត់មិនបានដើរតាមតុភ្ញៀវទេ គឺគាត់នៅតែកន្លែងកែសសៀ (ទទួលលុយ) រីឯកំណត់ហេតុទទួលស្គាល់វត្ថុតាងវិញ ក៏គាត់បញ្ជាក់ជូនក្រុមប្រឹក្សាហើយថា ពេលផ្តិតមេដៃសមត្ថកិច្ចមិនបានអានឲ្យស្តាប់ ហើយភ្នែកគាត់មើលមិនសូវឃើញច្បាស់ ដូច្នេះ ក្នុងនាមខ្លួនជាមេធាវីសំណូមពរសុំឲ្យសាលាឧទ្ធរណ៍ភ្នំពេញ មេត្តាសម្រេចឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ផារី រួចផុតពីបទចោទ ដោយក្តីអនុគ្រោះ ។

-ឈ្មោះ [redacted] ផារី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនការពារក្តីឲ្យឈ្មោះ [redacted] ថាវរិន ។ ក្រោយពីបានសិក្សាសំណុំរឿង និងស្តាប់ការសួរដេញដោលពេលសវនាការសាលាឧទ្ធរណ៍នេះ ខ្លួនយល់ឃើញថា ទីតាំងក្លឹបកំសាន្តនេះ កាលពីអតីតជារបស់លោកស្រីឧកញ៉ា [redacted] វុទ្ធី ហើយបានជួលមកឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ថាវរិន តាមកិច្ចសន្យា ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៨ លុះដល់ឆ្នាំ ២០១៩ ដោយសារមានបញ្ហាជម្ងឺសកល (កូវីត-១៩) ក៏សម្រេចបិទឈប់ធ្វើអាជីវកម្មទាំងស្រុង ហើយបានជួលទីតាំងបន្តទៅឲ្យឈ្មោះ [redacted] រតនា ភេទប្រុស តាមរយៈកិច្ចសន្យា ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០២០ ។

ផ្អែកតាមកិច្ចសន្យា ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២០ គឺឈ្មោះ [redacted] រតនា ជាអ្នកទទួលខុសត្រូវទាំងស្រុង មិនមែនកូនក្តីខ្លួនទេ ព្រោះសមត្ថកិច្ចចុះទៅបង្រ្កាបទីតាំងក្លឹបនោះនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២០ ។ នៅពេលសវនាការសាលាឧទ្ធរណ៍នេះ ឈ្មោះ [redacted] ផារី ក៏បានបញ្ជាក់ដែរថា នាងចូលធ្វើការលើកទីពីរ គឺថៅកែថ្មី ពុំមែនថៅកែចាស់ទេ វាស៊ីសង្វាក់គ្នានឹងការជួលទីតាំងបន្តទៅឲ្យថៅកែថ្មីមែន ហើយរឿងនេះ ក៏គ្មានភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនដែរ ដោយសារកូនកូនក្តីខ្លួនមិនបានប្រព្រឹត្ត ព្រោះជួលទីតាំងទៅឲ្យគេបាត់ហើយ



Scanned with CamScanner

ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាមេត្តាពិនិត្យពិចារណាសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ និង បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួន ។

-ឈ្មោះ [redacted] ច័ន្ទតារាវុធ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនការពារសិទ្ធិឲ្យឈ្មោះ [redacted] រតនា ។ ចំពោះការសន្និដ្ឋានរបស់លោកមេធាវីការពារសិទ្ធិឲ្យ ឈ្មោះ [redacted] ថាវរិន ដែលពាក់ព័ន្ធនឹងកិច្ចសន្យាជួលទីតាំងនោះ កូនក្តីខ្លួនសូមទទួលស្គាល់ ទាំងស្រុង ព្រោះកូនក្តីខ្លួនឈ្មោះ [redacted] រតនា បានជួលហាងបន្តពីឈ្មោះ [redacted] ថាវរិន ពិតមែន តែការគ្រប់គ្រងហាង (ក្លឹប) នោះ កូនក្តីខ្លួនពុំបានគ្រប់គ្រងផ្ទាល់ទេ គឺមានមេការ (អ្នកផ្សេង) ជាអ្នកមើលការខុសត្រូវ អញ្ចឹងកូនក្តីខ្លួនមិនបានដឹងរឿងលក់គ្រឿងញៀនក្នុងក្លឹបនោះទេ ហើយតុលាការបានផ្តន្ទាទោសលើកូនក្តីខ្លួនឈ្មោះ [redacted] រតនា យ៉ាងធ្ងន់ធ្ងរ និងពិន័យជា ប្រាក់យ៉ាងច្រើន ដែលការសម្រេចនោះ មានភាពអយុត្តិធម៌សម្រាប់កូនក្តីខ្លួន ព្រោះកូនក្តី ខ្លួនមិនបានដឹង និងមិនបានប្រព្រឹត្តអ្វីសោះ ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាមេត្តាសម្រេចឲ្យ កូនក្តីខ្លួនឈ្មោះ [redacted] រតនា រួចផុតពីបទចោទប្រកាន់ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា</u>

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០០៨ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ន, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៣៣ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២១ របស់មេធាវី [redacted] កនិកា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៥៨ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៦៤ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ របស់មេធាវី [redacted] ស៊ីលវីយ៉ោ និងមេធាវី [redacted] ពៅដារ៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាវរិន និងពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៦២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២១ របស់មេធាវី [redacted] ច័ន្ទសីហា និងមេធាវី [redacted] ចាន់ដារ៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាវរិន ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] យ៉ន និងឈ្មោះ [redacted] ដារ៉ា ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ១៩០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ យោងតាមមាត្រា ៣៧៣ មាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ទទួលយកសំណុំរឿងព្រហ្មទណ្ឌ លេខ ២៩៣ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ មកធ្វើការជំនុំជម្រះជាសមត្ថកិច្ច ។

//

Scanned with CamScanner

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ដារ៉ា និងឈ្មោ [redacted] យ៉ន ឆ្លើយថា ពួកខ្លួនប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ គឺដើម្បីឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស ។ ការស្នើសុំបន្ធូរបន្ថយទោសនេះ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា ពុំមានមូលហេតុត្រឹមត្រូវ ព្រោះថា ទោសពន្ធនាគាររយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន់) រៀល ដែលសាលាដំបូងរាជធានីភ្នំពេញ បានប្រកាសលើជនជាប់ចោទឈ្មោះ [redacted] ដារ៉ា និងទោសពន្ធនាគាររយៈពេល ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល គឺមានលក្ខណៈសមស្របទៅនឹងបរិមាណជាតុសុទ្ធនៃគ្រឿងញៀន ដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទទាំងពីររូប ។

៣-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] តារី ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ គឺដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ។ ចំពោះចម្លើយរបស់ខ្លួននៅសមត្ថកិច្ច គឺខ្លួនបានផ្តិតមេដៃ តែមិនបានអាន ។ ចំពោះចម្លើយរបស់ឈ្មោះ [redacted] ដារ៉ា ខ្លួនសុំបដិសេធ ។ ចម្លើយបដិសេធនេះ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ពុំអាចជឿជាក់បាន ព្រោះថា ជនជាប់ចោទបានឆ្លើយសារភាពនៅមុខសមត្ថកិច្ចថា ក្នុងក្លឹបកំសាន្ត ផ្លាយ មានការជួញដូរគ្រឿងញៀន ហើយគ្រឿងញៀននោះ គឺឈ្មោះ រតនា កូនចៅរបស់ឈ្មោះ ទូច យកមកប្រគល់ឲ្យខ្លួនដល់ក្លឹបតែម្តង ។ លុះដល់ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ខ្លួនបានប្រគល់គ្រឿងញៀនទៅឲ្យឈ្មោះ [redacted] យ៉ន គ្រប់គ្រង ដើម្បីលក់បន្តពីខ្លួន ដែលចម្លើយសារភាពនេះ មានលក្ខណៈស៊ីសង្វាក់គ្នានឹងចម្លើយរបស់ឈ្មោះ [redacted] យ៉ន និងឈ្មោះ [redacted] ដារ៉ា ព្រមទាំងកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន ដែលអាចឲ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ជឿជាក់បានថា ជនជាប់ចោទពិតជាបានជួញដូរគ្រឿងញៀននៅក្នុងក្លឹបកំសាន្ត ផ្លាយ ប្រាកដមែន ។

៤-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ដារ៉ិន ហៅ ទូច និងឈ្មោះ [redacted] តនា អវត្តមាន ។ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] យ៉ន និងចម្លើយរបស់ជនជាប់ចោទឈ្មោ [redacted] ធារី នៅសមត្ថកិច្ច ឃើញថា ជនជាប់ចោទទាំងពីររូប គឺជាមេជួញដូរគ្រឿងញៀននៅក្នុងក្លឹបកំសាន្ត ផ្លាយ ។

៥-ផ្អែកតាមសំអាងហេតុខាងលើ ឃើញថា សំអាងហេតុ និងសេចក្តីសម្រេចនៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ ១៥០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ មានមូលហេតុត្រឹមត្រូវ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញសម្រេចបដិសេធពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងប្រាំរូប ចោលជាអសារបង់ ព្រោះថា ទោសពន្ធនាគារដែលសាលាដំបូងរាជធានីភ្នំពេញ ប្រកាសចំពោះជនជាប់ចោទទាំងប្រាំរូប មានលក្ខណៈសមស្រប ទៅនឹងបរិមាណជាតុសុទ្ធនៃគ្រឿងញៀនដែលសមត្ថកិច្ចដកហូតបានពីក្នុងក្លឹបកំសាន្តផ្លាយ ។



Scanned with CamScanner

៦-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ថ្នាំញៀនត្រូវបានសមត្ថកិច្ចដកហូតបានពីជនជាប់ចោទ ហើយការផ្តន្ទាទោសរបស់សាលាដំបូងរាជធានីភ្នំពេញ គឺមានលក្ខណៈត្រឹមត្រូវ ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមនេះ ទុកជាបានការ ។ ការស្នើសុំនេះ មានមូលហេតុត្រឹមត្រូវ ផ្អែកតាមសំអាងហេតុខាងលើ ។

៧-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងប្រាំរូប នៅពេលសវនាការសាលាឧទ្ធរណ៍ភ្នំពេញ ពុំមានមូលហេតុត្រឹមត្រូវ ផ្អែកតាមសំអាងហេតុខាងលើ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-បដិសេធពាក្យបណ្តឹងឧទ្ធរណ៍លេខ ០០៨ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ន, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៣៣ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២១ របស់មេធាវី [redacted] កនិកា ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ ឃាង ដារ៉ា, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៥៨ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៦៤ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២១ របស់មេធាវី [redacted] ស៊ីលវីយោ និងមេធាវី [redacted] ពៅដារ៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាវរិន និងពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៦២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២១ របស់មេធាវី [redacted] ច័ន្ទសីហា និងមេធាវី [redacted] ចាន់ដារ៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាវរិន ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] យ៉ន និងឈ្មោះ [redacted] ធារី ចោលជាអសារបង់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩០៣ "ណ" ក្រ៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ឈ្មោះ [redacted] ធារី និងឈ្មោះ [redacted] យ៉ន តាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ឈ្មោះ [redacted] ធារី និងឈ្មោះ [redacted] យ៉ន កំបាំងមុខជនជាប់ចោទឈ្មោះ សេង ថាវរិន និងឈ្មោះ ម៉ៅ រតនា និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ឈ្មោះ [redacted] ធារី និងឈ្មោះ [redacted] យ៉ន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ថាវរិន និងឈ្មោះ [redacted] រតនា ទុកសិទ្ធិឲ្យប្តឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 14 ខែ 12 ឆ្នាំ ២០២១

| បានឃើញ | |
|---|---|
| ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ក្រឡាបញ្ជី |
| [redacted] | [redacted] |

Scanned with CamScanner